# គំរោងមេរៀនសំរាប់គ្រូ

សូមមើលទំព័រទំព័រទី១ និងទី២  នូវ របៀបប្រើសៀវភៅរបស់គ្រូជាពតិមានបន្ថែមស្តីពីការប្រើផែនការនេះ។

# បញ្ជីកិច្ចការនៅក្នុងថ្នាក់រៀន

**ចំណងជើងមេរៀន:** **ការអនុវត្តន៍របស់គ្រីស្ទបរិស័ទ**

**លំហាត់**

| **ខគម្ពីរសំរាប់ចងចាំ** | **ថ្ងៃ ខែ ឆ្នាំ** |
|---|---|
| ១. អេភេសូ៤:២៩ | ថ្ងៃទី២ |
| ២. ២កូនរិនថូស៩:៧ | ថ្ងៃទី៣ |
| ៣. កូឡូស៣:២៣ | ថ្ងៃទី៤ |

កិច្ចការ

**ថ្ងៃ ខែ ឆ្នាំ**

១. ថ្ងៃទី១
២. ថ្ងៃទី២
៣. ថ្ងៃទី៣
៤. ថ្ងៃទី៣
៥. ថ្ងៃទី៤
៦. ថ្ងៃទី៥

**ការប្រលង** ថ្ងៃ ខែ ឆ្នាំ ថ្ងៃ៧

# មេរៀនទី ១ :　　ព្រះវិហារនៅតាមតំបន់

**១. គន្លឹះសេចក្តីពិតនៅក្នុងព្រះគម្ពីរ**

ខ្ញុំអាចចូលរួមក្នុងព្រះវិហារ និង សំណេះសំណាលជាមួយបងប្អូន ។

**២. ខគម្ពីរជាគន្លឹះ**

អេភេសូ៤:១៦

" គឺព្រះអង្គហើយដែលធ្វើអោយរូបកាយទាំងមូលបានផ្គុំគ្នា និង ភ្ជាប់គ្នាឡើងយ៉ាងមាំដោយសារសន្លាក់ឆ្អឹងទាំងប៉ុន្មានដែលបំរើព្រះកាយតាមករិតសមត្ថភាព របស់សេរីរាង្គនិមួយៗ ដើម្បីអោយព្រះកាយនោះចំរើន និងកសាងឡើងក្នុងសេចក្តីស្រលាញ់ " ។

**៣. ឯកសារយោងរបស់សិស្ស**

ទំព័រទី ៣-៧ ក្នុងសៀវភៅនៃនាំរបស់សិស្ស ស៊ីគ្នាទៅនឹងមេរៀននេះ ។

**៤. ការរៀបចំរបស់សិស្ស**

ប្រើក្នុងកិច្ចការទី១ ដោយធ្វើការពិភាក្សាដោយសង្ខេប ទៅនឹងនិយមន័យខុសគ្នារបស់ពាក្យថា " ព្រះវិហារ" ។មើលទំព័រទី៣ នៃសៀវភៅរបស់សិស្សសំរាប់ជាពតិបន្ថែម ។

**៥. ធ្វើអោយមេរៀននេះកាន់តែងាយស្រួល**

បង្ហាញមូលហេតុដ៏សំខាន់ពីរដោយសង្ខេប ថាតើហេតុអ្វីបានជាយើងមានព្រះវិហារនៅតំបន់ ។ ព្យាយាមពន្យល់ត្រលប់មករកអត្ថន័យជាពិសេសមេរៀននេះទាំងមូល ។

**៦. បង្ហាញចំនុចគ " តើខ្ញុំអាចចូលរួមព្រះវិហារដោយរបៀបណា ? "**

ត្រូវប្រញាប់បង្ហាញតាមសេចក្តីណែនាំបួន ឬ ចំនុចសំខាន់ជាច្រើនទៀត បន្ទាប់មកត្រលប់មក ចូលមករក ចំនុចដើមវិញ គឺ ធ្វើអោយចំនុចដែលយើង កំពុងតែបង្រៀននេះមានភាពលំអិតកាន់តែប្រសើរ ។

**៧. ១កូរិនថូស១៣:៤-៨**

ប្រើព្រះគម្ពីរ ១ កូរិនថូស ១៣:៤-៨ ហើយសរសេរពី កិរិតស្តីពីបទសន្ទនារបស់ពួកគេជាមួយបងប្អូននៅព្រះ វិហារ ។

**៨.ការសុំផ្ទាល់ខ្លួន**

ដើម្បីធ្វើអោយការងារដំណើរទៅដោយសកម្មហើយ អ្វីដែលទាក់ទងទៅនឹងសំភារៈ អនុញ្ញាតអោយគេធ្វើសំណើទៅព្រះវិហារនៅតាមតំបន់ របស់ពួកគេ ។ បើនិស្សិតត្រូវបានរៀន ហើយស្នាក់នៅក្នុងមជ្ឈមណ្ឌល ( ធីរ ឆា ឡិន )នោះអនុញ្ញាតអោយគេទំនាក់ទំនងទៅមជ្ឈមណ្ឌល ។

**៩. សង្កត់ទៅលើសារៈសំខាន់នៃការរីកចំរើនបទសន្ទនាល្អជាមួយគ្រីស្ទបរិស័ទ ដទៃទៀត ។**

**១០. វែកញែកពីសេចក្តីដែលបណ្តាលអោយមានគ្រោះថ្នាក់ដោយសារតែការដដែកពីជីវិតអាក្រក់នៅក្នុងអតីតកាលរបស់ពួកគេ។**

## ១១. កិច្ចការៈ

ក. ថ្ងៃនេះចែកសៀវភៅអោយសិស្ស

ខ. កែកិច្ចការទី១

គ. ពន្យល់កិច្ចការដល់សិស្សដែលមានបំណងផ្តល់គំនិតខ្លះៗ នូវរបៀបដែលគេអាចដោះស្រាយចំពោះបញ្ហាពិសេសៗ ដែលកើតឡើងទៅក្នុងជីវិតប្រចាំថ្ងៃផ្ទាល់របស់ពួកគេ ។

## ១២. ធ្វើការវាយតំលៃនៅលើមេរៀន

សូមសរសេរដោយវាយតំលៃលើកាវិវឌ្ឍន៍មេរៀននេះ និងរៀបចំជាស្រេចសំរាប់ជាការងារបន្ទាប់ ។

ជំរៅនៃកិច្ចការ

**ការកត់ចំណាំ**

## តើព្រះវិហារជាអ្វី *

មានពាក្យបីអាចប្រើ ជាចំលើយសំរាប់សំនួរៈ

បំនង . គោលការណ៍ និងកម្មវិធី ។

**Iបំណងៈ** តើហេតុអ្វីបានជាយើងមានព្រះវិហារ?

តើព្រះជាម្ចាស់និងមានព្រះបន្ទូលយ៉ាង ដូចម្តេច បើសិនអ្នកទូលសួរព្រះអង្គថា ហេតុអ្វីព្រះអង្គចាប់ផ្តើមសង់ព្រះវិហារ?

១. ជួយគ្រីស្តបរិស័ទពិតប្រាកដ

២. ជួយអ្នកដទៃអោយក្លាយទៅជាគ្រីស្តបរិស័ទមានគោលបំណងធំធេងណាស់ចំពោះព្រះវិ ហារ គោលគឺទិសដៅទី១ ត្រូវតែឈានទៅមុខទើបចំនុច ទើបចំនុចទីពីអាចឈានទៅបាន ។បើទិសដៅទីមួយរីកទៅមុខ ហើយទិសដៅទីពី ក៏រីកទៅមុខដោយស្វ័យប្រវត្តិ ដែរ ។

**IIគោលការណ៍:** ទាំងនេះបរិយាយ របៀបដែលយើងអាចបំពេញគោលបំណងរបស់យើង ។

១. ការប្រកប

២. ថ្វាយបង្គំនិងអធិស្ឋាន

៣. អំណោយរបស់ព្រះវិញ្ញាណដ៏បរិសុទ្ធ

**១. <u>ការប្រកប</u> :** ចែកចាយជាមួយអ្នកដទៃ

●ការទុកចិត្តនិងជំនឿ ●បញ្ហារបស់ខ្ញុំ ●ជ័យជំនះរបស់ខ្ញុំ

បងប្អូនដែលអញ្ជើញទៅចូលរួមឯព្រះវិហារ ក្នុងចំនោមពួកគេមានអ្នកខ្លះមានទុក្ខលំបាក នៅក្នុងជីវិត ។ ដូច្នេះពួកគេចង់ឃើញការនិយាយសស្តីណាដែល ផ្តល់នូវការលើកទឹកចិត្ត និងចុះសម្រុងនឹងគ្នា ។

**<u>២.ថ្វាយបង្គំ និងអធិស្ឋាន</u>**

ថ្វាយបង្គំគឺជាកិច្ចការទូលថ្វាយដល់ព្រះជាម្ចាស់នូវ អ្វីដែលខ្ញុំចូលចិត្ត អំពីព្រះជាម្ចាស់ ។ ការថ្វាយបង្គំអាចធ្វើអោយ កាន់តែស្គាល់ព្រះអង្គនិងកាន់តែមានន័យនៅក្នុងជីវិតរបស់ខ្ញុំ ។

**<u>៣. អំណោយរបស់ព្រះវិញ្ញាណដ៏បរិសុទ្ធ</u>**

អំណាចនេះអាចប្រើសំរាប់ការងារឬស្ថានការណ៍ការងារ ដើម្បីជំរុញគ្រីស្តបរិស័ទអោយចែកចាយទៅដល់អ្នកដទៃនូវអំណោយទានទាំងឡាយដែលគេមាន ។

## IIIកម្មវិធី

ជារបៀបមួយឬការបំរើព្រះជាម្ចាស់ទូទៅនិងទំរង់រចនាសម្ពន្ធ័តាមរយៈអង្គការនានា ។ តើកម្មវិធីនេះជួយឬបង្អាក់ដល់អភិវឌ្ឍន៍នៃព្រះវិហារដែលព្រះជាម្ចាស់សព្វព្រះហឫទ័យធ្វើ ។

**ការកត់ចំណាំទាំងនេះបានដកស្រង់ចេញពីសិក្ខាសិលាមួយនៅព្រះវិហារ ឌីណាមិច។

●អេភេសូ ២:១៨-២០

●១ថេសាឡូនិច ៥:១២-១៣

●១កូរិនថូស១២:១២-១៤ , ២៧

**ក.** ពាក្យថា " **ព្រះវិហារ** " ជាពាក្យភាសានិយមដែលបង្កប់ដោយអត្ថន័យច្រើន។ វាអាចមាន ន័យថា ជាអាគារសំរាប់ថ្វាយបង្គំ ក្រុមជំនុំ និកាយ គ្រីស្ទអាណាចក្រនិងការ បំរើពាក់ព័ន្ធនិង សាស នា ។ មានពាក្យពីជាគំរូស្រោប់ គឺ **អាឃ្លនីសស៊ីម** និង **អឃ្លារាយសេសិន**( ភាសាអង់គ្លេស) ។

**1. អឃ្លានីសស៊ីម :**ជាព្រះវិហារដែលមានន័យថា "ហៅអ្នកជឿដែលមានព្រះកាយរបស់ព្រះយេស៊ូ គ្រីស្ទ "

**2.អឃ្លាណាយសេសិន :** ជាព្រះវិហារដែលមានន័ថា " ជាកន្លែងដែលអ្នកជឿជាព្រះកាយ របស់ ព្រះយេស៊ូគ្រីស្ទជួបជុំគ្នាថ្វាយបង្គំព្រះជាម្ចាស់ ដោយវិញ្ញាណនិងសេចក្តីពិត " ។

**ខ.** ព្រះវិហារត្រូវចាក់គ្រឹះលើអង្គព្រះយេស៊ូគ្រីស្ទ មិនមែនលើអង្គណាផ្សេងទៀតទេ។ ព្រះគម្ពីរ ១កូរិនថូស៣:១១ " ត្បិតគ្មាននរណាអាចចាក់គ្រឹះមួយផ្សេងទៀតក្រៅពីគ្រឹះដែលបានចាក់រួចមក ហើយនោះទេ ពោល គឺព្រះយេស៊ូគ្រីស្ទ " ។ យើងអាចប្រៀបធៀបទៅនឹងព្រះគម្ពីរ១ ពេត្រុស២ :៦-៨។

**គ.** ព្រះវិហារមិនមែនគ្រាន់តែជាអាគារសំរាប់ពះគ្រីស្ទគង់នៅ ឬ ជាកន្លែងដែលបានចាក់ឬសរឹងមាំ ប៉ុណ្ណោះទេ ប៉ុន្តែជារូបកាយដែលព្រះអង្គប្រោសប្រទានអោយបានបរិសុទ្ធ។ ព្រះវិហារជាព្រះកាយនៃ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះគ្រីស្ទ។( ព្រះគម្ពីរកូឡូស១ :១៨ . អេភេសូ ១:២២ . ២៣ ៥:២៣ . ២៤ ) ។

**ឃ.**ព្រះវិហារប្រៀបបានទៅនឹងភរិយាផងដែរ ( ព្រះគម្ពីរអេភេសូ ៥:២៥-៣២ ) ។ បំនងនេះចង់ បង្រៀនពីរចនាសម្ពន្ធ័ចំពោះក្រុមគ្រួសារ ហើយតាមរយៈការបង្រៀននៃខគម្ពីរទាំងនេះគឺជាភរិយា ត្រូវចេះគោរពស្វាមីរបស់ខ្លួន ហើយស្វាមីត្រូវចេះស្រលាញ់ភរិយាដូចព្រះគ្រីស្ទស្រលាញ់ក្រុមជុំនុំ ព្រះ សហគមន៏អញ្ចឹងដែរ។ សរុបមកព្រះគ្រីស្ទគឺជា :

1. ចំពោះអាគារព្រះគ្រីស្ទជាគ្រឹះ
2. ចំពោះរូបកាយព្រះគ្រីស្ទជាព្រះសិរសា
3. ចំពោះស្ត្រីព្រះគ្រីស្ទជាអនាគត ។

**ង.** សាមាជិកព្រះវិហារដែលបានទទួលព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួន ( ព្រះគម្ពីរ១កូរិនថូស ១២:១៣ ) ហើយចង់ក្លាយជាព្រះវិហាររបស់ព្រះអង្គ មានតែការកើតជាថ្មីនិងរួម បទពិសោធន៏ ជាមួយទ្រង់។

**ច.** កាលមាននរណាម្នាក់ចូលរួមជាព្រះវិហារ របស់ព្រះយេស៊ូគ្រីស្ត នោះគាត់នឹងមានកាតព្វកិច្ចឬផ្នែករួមបំរើព្រះវិហារ ។ គាត់អាចសាងសង់ជំនឿ ឬ បំពេញការត្រាស់ហៅរបស់ព្រះជាម្ចាស់នៅ ក្នុងជីវិតរបស់គាត់។

**ឆ.** ព្រះគម្ពីរអេភេសូ ៤:១១-១៣ បង្រៀនយើងថា តើហេតុអ្វីបានជាទៅចូលរួមនៅឯព្រះវិហារ ជារឿងសំខាន់ហើយ ហេតុអ្វីបានជាព្រះជាម្ចាស់សព្វព្រះហឫទ័យអោយយើង ម្នាក់ធ្វើដូច្នេះ។

**ជ.** តួនាទីរបស់ព្រះវិហារនៅតាមតំបន់នានាគឺ :

1. នាំដំណឹងល្អគ្រប់ទីកន្លែងក្នុងពិភពលោក ម៉ាកុស ១៦: ១៥
2. ពង្រឹងវិស័យដឹកនាំ អេភសូ ៤:៧-៨

៣. បំរើទៅតាមអំណោយទានដែលយើង មាននៅក្នុងព្រះគ្រីស្ត ១កូរិនថូស ១២:២៨ , រ៉ូម ១២:៦-៨

4. ត្រូវរកកន្លែងថ្វាយបង្គំ កិច្ចការ២០: ៧ ហេប្រឺ ១០:២៥
5. រៀបចំការងារធ្វើយ៉ាងណាអោយសមាជិកម្នាក់ៗចេះ បរិច្ចាកពេលវេលា ការប៉ិនប្រសប់ និងប្រាក់កាសថ្វាយដល់ព្រះជាម្ចាស់ រ៉ូម១៥:២៦ ១កូរិនថូស ១៦:១,២
6. ផ្តល់ទីកន្លែងសំរាប់សកម្មភាពកិច្ចការរបស់គ្រីស្តបរិស័ទ ។ ១ ធីម៉ូថេ ៥:៩ កិច្ចការ ៦:១ ,ម៉ាថាយ ២៥:៣៧-៤០
7. ផ្តល់ទីកន្លែងជាជំរកដល់ពួកគេជាបងប្អូនក្នុងគ្រួសារជាបទពិសោធន៏ បងប្អូនរួមជំនឿត្រូវស្រលាញ់រាប់អានអោយបានស្មើៗគ្នា។

# មេរៀនទី២:　　ទីបន្ទាល់

## ១. គន្លឹះសេចក្តីពិតនៅក្នុងព្រះគម្ពីរ

នៅពេលដែលខ្ញុំធ្វីទីបន្ទាល់ ខ្ញុំអាចចែកចាយជាមួយបងប្អូនដទៃនូវរបៀបដែលព្រះជាម្ចាស់ជួយខ្ញុំ។

## ២. ខគម្ពីរជាគន្លឹះ :

**អេភេសូ ៤:២៩**

*កុំអោយមានពាក្យអាស្រូវណាមួយចេញពីមាត់បងប្អូនឡើយ ផ្ទុយទៅវិញ ត្រូវអោយនិយាយពាក្យដែលជួយកសាងជំនឿអ្នកដទៃ ប្រសិនបើគេត្រូវការ ព្រមទាំងផ្តល់ប្រយោជន៍ដល់អ្នកស្តាប់ផងដែរ។*

## ៣. ឯកសារយោងរបស់សិស្ស:

ទំព័រទី៨- ១១ក្នុងសៀវភៅរបស់សិស្សស៊ីគ្នាទៅនឹងមេរៀននេះ។

## ៤. ធ្វើអោយមេរៀននេះកាន់តែងាយស្រួល:

ដំបូងបង្អស់ត្រូវធ្វើការពិភាក្សាទៅលើនិយមន័យនៃ ពាក្យ " **ទីបន្ទាល់** " អនុញ្ញាតអោយពួកគេ រំពឹងទៅ លើគំនិតដែលគេបាន ដាក់នៅក្នុងកិច្ចការទី១ ។ បន្ទាប់ពីគេបានផ្តល់គំនិតជាចំលើយ អស់ហើយ បង្ហាញគេ នូវអត្ថន័យនៃនិយមន័យ ដូច្នេះគេអាចយល់កាន់តែច្បាស់ នូវអ្វីដែលហៅថា ទីបន្ទាល់។ មិនត្រឹមតែប៉ុណ្ណឹង អ្នកអាចសរសេរនិយមន័យដាក់លើផ្ទាំងក្រដាសធំហើយភ្ជួរក្នុងថ្នាក់។

**ទីបន្ទាល់**

ចែកចាយជាមួយអ្នកដទៃ ពីព្រះគ្រីស្ត ដែលកំពុង ធ្វើការក្នុងជីវិតរបស់ខ្ញុំ ។

## ៥. ពន្យល់ដល់សិស្សអ្វីទៅដែលមិនមែនជាទីបន្ទាល់

បង្ហាញទិសដៅអោយច្បាស់លាស់ ទីបន្ទាល់មិនមែនជា ប្រវត្តិជីវិតទេ តែជាជីវប្រវត្តិ។ ប្រាប់ពួកគេអោយសរសេរចូលក្នុងសៀវភៅ បើសិនគេចង់ អោយមនុស្សឮពីប្រវត្តិរបស់ពួកគេ ។

## ៦.បង្ហាញពីចំនុច គ

ប្រញ្ជាប់ពិភាក្សាលើចំនុច គ " ***ជាចំនុចសំខាន់ៗ ដែលជាទីបន្ទាល់ល្អ*** "។ សូមមើលទំព័រទី៨ ក្នុងសៀវភៅរបស់សិស្ស សំរាប់ចំនុចលំអិតលើបញ្ហានេះ ។

## ៧.ចំណាយពេលអោយបានច្រើនបំផុតនៅក្នុងការបញ្ជាក់ពីទីបន្ទាល់ល្អៗ

## ៨. គំរូសិក្សាពីជីវិតមួយទៅជីវិតមួយ

ចង្អុលបង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និតនៃទីបន្ទាល់ល្អដែលទាក់ទងទៅនឹងគំរូសិក្សាពីជីវិតមួយទៅជីវិតមួយ។ សូមមើលទំព័រទី៩នៃសៀវភៅរបស់សិស្សហើយចំលងយកមួយសន្លឹក។

## ៩. ចំនុចចំណាំផ្ទាល់របស់គ្រូ

សូមមើលចំនុចចំណាំជំរៅនៃកិច្ចការរបស់គ្រូ នៅទំព័របន្ទាប់ជាពតិមានបន្ថែមក្នុងការធ្វើទីបន្ទាល់។

## ១០. ការសុំផ្ទាល់ខ្លួន

សំរាប់ជាសុំជាផ្ទាល់ខ្លួន គួរលើទឹកចិត្តពួកគេ អោយធ្វើទីបន្ទាល់ ប្រភេទដូចនេះទោះជានៅក្នុងព្រះវិហារ ឬនៅក្នុងការរៀនព្រះគម្ពីរជាក្រុមក៏ដោយ ។

## ១១. កិច្ចការ

ក. នៅខាងចុងម៉ោងសិក្សាត្រូវដាក់អោយលំហាត់អោយគេធ្វើ ដែលមាននៅក្នុងព្រះគម្ពីរអេភេសូ ៤:២៩។

ខ. កែកិច្ចការទី២ ត្រូវកត់ចំណាំគោលបំណងនៃកិច្ចការ នេះផ្តល់គំនិតខ្លះ១ទូវរបៀប ដែលគេអាចដោះស្រាយជាមួយ ខគម្ពីរសំខាន់១និងយកទៅអនុវត្តក្នុងជីវិតរស់នៅប្រចាំថ្ងៃ របស់ពួកគេអាចផ្តល់នូវផ្លូវផ្សេងខ្លះទៀតដែលអាចជួយដល់កិច្ចការនេះទំរាំដល់ម៉ោងបញ្ចប់ បើសិនគេចង់បានពតិមានបន្ថែមដើម្បីយកទៅប្រើក្នុងទីបន្ទាល់ របស់ពួកគេក្នុង កិច្ចការទី៣ ។

## ១២. ការវាយតំលៃលើមេរៀន

សូមសរសេរការវាយតំលៃ លើការវិវឌ្ឍន៍នៃមេរៀននេះ និងរៀបចំជាស្រេចសំរាប់កិច្ចការបន្ទាប់។

ជំរៅនៃកិច្ចការ

ការកត់ចំណាំ

**ការពន្យល់មេរៀននៅលើទីបន្ទាល់របស់អ្នក**

១. មិនត្រូវនិយាយអំពីអ្វីដែលព្រះជាម្ចាស់ **អនុញ្ញាត** ឬមានបន្ទូល**ប្រាប់**ពួកគេឡើយ ប៉ុន្តែត្រូវ និយាយពីអ្វីដែលព្រះជាម្ចាស់បាន**ជួយ**ក្នុងការធ្វើអ្វីមួយ ។

២. មនុស្សដែលស្តាប់ទីបន្ទាល់របស់អ្នកគួរតែនិយាយថា :

" ខ្ញុំចង់ធ្វើអ្វីដែលអ្នកបានធ្វើ ហើយនឹងអ្វីដែលអ្នកបានប្រាប់យើងថ្ងៃនេះ "

" ខ្ញុំ ចង់ប្រត្តបត្តិតាមអ្នក "

" អរគុណអ្នកដែលបង្រៀន នូវរបៀបរស់នៅ "

" អរគុណអ្នកដែលបង្ហាញខ្ញុំនូវរបៀបប្រើព្រះគម្ពីរ ដើម្បីជួយអោយបានលូតលាស់ "

មនុស្ស មិនអាចនិយាយពាក្យទាំងនេះកើតទេ បើសិនណាខ្ញុំចែកចាយជាមួយពួកគេតែពីជីវិតនិង អំពីតែបាបដែលខ្ញុំប្រព្រឹត្តនៅក្នុងជីវិតអតតីកាលរបស់ខ្ញុំ បើគេធ្វើតាមអ្វីដលខ្ញុំបានចែកចាយគេមុខ ជាធ្វើតែបាប ។ ទីបន្ទាល់និមួយៗគួរតែធ្វើអោយមនុស្សកាន់តែ សប្បាយរីករាយ អំពីសេចក្តីស្រលាញ់និង ការបំរើ ព្រះជាម្ចាស់ ។

៣.ព្រះគម្ពីរអេភេសូ ៤:១៦ ហើយនៅខាងចុងប្រយោគនៃ ខគម្ពីរនេះ ប្រាប់យើងនូវរបៀបដែល យើងអាចជួយព្រះវិហារអោយរីកចំរើនឡើងក្នុងសេចក្តីស្រលាញ់ ។

៤. ចែកចាយពីចំនុចលំអិតពីជីវិតអតតីកាល របស់ខ្ញុំនឹងធ្វើអោយមនុស្សដឹងនូវ របៀបងាកចេញ ពីអំពើបាប អេភេសូ ៤:២៩ ប្រាប់យើងនូវរបៀបជួយពួកគេអោយកាន់តែរឹងមាំក្នុង ភាពជា គ្រីស្តបរិស័ទ ។

ជំរៅនៃកិច្ចការ

កំណាតចំណាំ

**តើទីបន្ទាល់របស់ខ្ញុំធ្វើអោយព្រះវិហារនៅជាកន្លែងសំណើចឬ ?**

១. ពេលដែលខ្ញុំនិយាយអំពីជីវិត ប្រព្រឹត្តអំពើបាប នៅក្នុងជីវិតអតតីកាលរបស់ខ្ញុំ ធម្មតាខ្ញុំអាចនាំ មនុស្សនិយារឿងកំសាន្តទៅវិញ ( មនុស្សម្នាចូលចិត្តការកំសាន្ត ) ។ការនេះ វាហាក់បីដូចជា គ្រាន់តែចូលរួមកន្លែងសំណោចឬ កំសាន្ត ឯស្នូនសត្វប៉ុណ្ណោះ ។ " សូមមើលមកខ្ញុំ ! មើល អ្វីដែលខ្ញុំបានធ្វើ" ព្រះជាម្ចាស់មិនមែនជាកន្លែងសំណើចឬសួនសត្វ សំរាប់កំសាន្តនោះទេ ។ ព្រះអង្គជាអ្នកដឹកនាំព្រះវិហារ ។គោលបំណងសំខាន់ នៃព្រះវិហារនៅតាមតំបន់គឺជួយ គ្រីស្ត បរិសទ័ អោយ ដុះដាលរឹងមាំឡើង.

២. ទីបន្ទាល់របស់ខ្ញុំនិងជួយអ្នកដទៃឬទេ បើសិនខ្ញុំបង្ហាញនូវរបៀបដែលព្រះជាម្ចាស់កំពុងតែជួយខ្ញុំ អោយរីកចំរើន ។

នេះមានមាននៅក្នុងកត់ចំណាំបន្ថែមខ្លះទៀតដែលស៊ីគ្នាទៅនឹងផ្នែកជាច្រើន នៃមេរៀននោះ ។ ចំនុច ខ និង គ ទាក់ទងជាច្រើននៅក្នុងសៀវភៅរបស់សិស្ស ។ ចង្អុលបង្ហាញនៅក្នុងនូវពតិមានបន្ថែម

លើកយកបង្ហាញនៅក្នុងថ្នាក់ បើសិនអ្នកមានពេលគ្រប់គ្រាន់។

ខ. តើហេតុអ្វីខ្ញុំគួរធ្វើជាទីបន្ទាល់

១. ជួយអ្នកដទៃអោយមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ក្នុងជីវិតរបស់ពួកគេ។

២. ថ្វាយសេរីរុងរឿងដល់ព្រះជាម្ចាស់ ព្រោះនាមរបស់ព្រះអង្គ គួរអោយសរសើរ ។

៣. ជួយខ្ញុំអោយក្លាយជាគ្រីស្ទបរិស័ទកាន់តែរឹងមាំ។

គ. តើចំនុចសំខាន់អ្វីខ្លះសំរាប់ទីបន្ទាល់ល្អ ?

ផ្នែកសំខាន់បំផុតនៃទីន្ទាល់របស់ខ្ញុំ ជាចំនុចពិសេសគំរុ មួយប្រចាំថ្ងៃដែលព្រះជាម្ចាស់ជួយខ្ញុំអោយ ដោះដាល។

១. ចំនុចពិសេសដូចជា :

- កំពុងតែកែខ្លួនឯង
- កំហឹង
- ការប៉ុនប៉ង
- ភាពកំជិល
- ចិត្តគំនិតចំពោះអ្នកដឹកនាំ

២. ដំបូងចែកចាយយ៉ាងសង្ខេបថាអ្វីដែលអ្នកមានពីមុនព្រះជាម្ចាស់បានជួយជីវិតរបស់អ្នកអោយ ដោះដាលឡើង។

៣. ពន្យល់នូវរបៀបដែលព្រះជាម្ចាស់អ្នកបានធំធាត់:

ក. ប្រាប់របៀបនៃសកម្មភាព ដែលអ្នកបានប្រើក្នុងការជួយអោយអ្នកអោយរីកចំរើន។

ខ. ប្រាប់ខគម្ពីរណាមួយដែលបានជួយអ្នក

៤. ផ្តល់គំរូខគម្ពីរសំខាន់មួយនិងបង្ហាញរបៀបនៃសកម្មភាពដែលអ្នកបានប្រើក្នុងខគម្ពីរនេះ។

៥. ប្រាប់មេរៀនដែលអ្នកបានរៀនពីបទពិសោធន៍នេះ។ ពន្យល់របៀបដែលវាជួយអ្នក អោយកាន់តែជិតស្និតជាមួយព្រះជាម្ចាស់។ ឬ នេះពិតជាទាក់ទងទៅនឹងគោលការណ៍ថា " សិក្សាពីជីវិតមួយទៅជីវិតមួយ " ។

ឃ. តើកន្លែងណាមួយខ្ញុំអាចធ្វើបន្ទាល់?

១. ព្រះវិហាររបស់ពួកយើង

២. ក្នុងគ្រួសារខ្ញុំ បើអ្នកមិនរស់នៅជាមួយពួកគេទេចែកចាយនៅពេលទៅសួរសុខទុក្ខឬតាមការសរសេរសំបុត្រ ។

៣. មនុស្សម្នាដែលរស់នៅជិតខ្ញុំ ( ជាពិសេសអ្នកថ្មីៗ ) ។

៤. អ្នកនៅបន្ទប់ជាមួយ

៥. ការជួបជុំជាក្រុម

៦. ពេលញុំាអាហារ

៧. ពេលទំនេរ

# មេរៀនទី៣ៈ   អ្នកចាត់ការសំរាប់ព្រះជាម្ចាស់

**១. គន្លឹះសេចក្តីពិតក្នុងព្រះគម្ពីរ ៈ**

ក្នុងនាមជាអ្នកចាត់ការសំរាប់ព្រះជាម្ចាស់ ខ្ញុំត្រូវធ្វើអោយបានល្អបំផុត គ្រប់ភារៈកិច្ចទាំងអស់។

**២. ខគម្ពីរជាគន្លឹះ ៈ**

**ព្រះគម្ពីររ៉ូម ១២ៈ ១១**

*" ត្រូវឧស្សាហ៍ខ្នះខ្នែង កុំលច្រអូសឡើយ។ ត្រូវបំរើព្រះអម្ចាស់ដោយចិត្តក្លៀវក្លា ។ "*

**៣. ការរៀបចំរបស់គ្រូ ៈ**

ទំព័រទី១២ - ១៨ ក្នុងសៀវភៅរបស់សិស្សស៊ីគ្នាទៅនឹងមេរៀននេះ។

**៤. ការបង្ហាញពីចំនុច ក ( ៥-១០នាទី )**

ដំបូងពិភាក្សាយ៉ាងសង្ខេប អ្វីដែលហៅថា អ្នកចាត់ការ និង អ្វីដែលគាត់ត្រូវធ្វើ។ សូមមើលការកត់ចំនាំជំរៅកិច្ចការរបស់គ្រូសំរាប់ជាគំនិតបន្ថែម។

**៥. បង្ហាញពីចំនុច គ (៥ -១០នាទី )**

បង្ហាញយ៉ាងសង្ខេបនូវរបៀបដែលព្រះជាម្ចាស់ ប្រទានអោយខ្ញុំចាត់ការ។ ចង្អុលបង្ហាញទៅលើចំនុច **ខ** ព្យាយាមសង្កត់ធ្ងន់ទៅលើការពិភាក្សាពីអ្វីដែលព្រះជាម្ចាស់ ប្រទានអោយពួកគេចាត់ការនៅក្នុងថ្នាក់ឥឡូវ នេះ។ សូមមើលការកត់ចំណាំជំរៅកិច្ចការរបស់គ្រូជាគំនិតបន្ថែម លើកិច្ចការនេះ។ មិនត្រូវបន្តចំនុចពិភាក្សា ទាំងនេះ រហូតដល់ចំនុច **ឃ** ឡើយ តែជំនួសការនេះ អ្នកអាចពិភាក្សា ក្នុងចំនុចលំអិតនូវរបៀបពួកគេអាច
បង្ហាញ ព្រះជាម្ចាស់ថាពួកគេជាអ្នកចាត់ការដ៏ល្អសំរាប់ព្រះអង្គ។

**៦. បង្ហាញពីចំនុច គ ( ៥-១០នាទី )**

" តើអ្វីដែលធ្វើអោយមនុស្សក្លាយទៅជាអ្នកចាត់ការដ៏ល្អរបស់ព្រះជាម្ចាស់ ? "

**៧. បង្ហាញពីចំនុច ឈ ( ៥ -១០នាទី )**

ចំណាយពេលអោយបានច្រើនបំផុត នៅក្នុងថ្នាក់ចំពោះការសិក្សា លើចំនុច **ឃ** " តើខ្ញុំអាចបង្ហាញតាមរបៀប ណាថាខ្ញុំជាអ្នកចាត់ការដ៏ល្អរបស់ព្រះជាម្ចាស់ ? "

**៨. បង្ហាញពីចំនុច ង និង ច**

បើអ្នកមានពេល អ្នកពិភាក្សាលើចំនុច **ង** " ចិត្តគំនិតរបស់ខ្ញុំត្រូវប្តេជ្ញា បើខ្ញុំធ្វើការជាអ្នកចាត់ការសំរាប់ ព្រះជាម្ចាស់ " និង " ចំនុច **ច** " លទ្ធផលរបស់អ្នកចាត់ការសំរាប់ព្រះជាម្ចាស់ " ។

**៩. ការសុំផ្ទាល់ខ្លួន**

សង្កត់ធ្ងន់ទៅលើការសុំផ្ទាល់ខ្លួន ក្នុងនាមជាអ្នកចាត់ការសំរាប់ព្រះជាម្ចាស់ នៅក្នុងថ្នាក់។ ពិនិត្យអោយម៉ត់ចត់ឡើងវិញនូវអ្វីដែលព្រះជាម្ចាស់ព្រះទានអោយ ពួករគេចាត់ចែងផ្ទាល់ទាក់ទងទៅនឹងពេលវេលាក្នុងថ្នាក់ នេះ។

ផ្តល់អោយគេនូវសេចក្តីបញ្ជាក់ខ្លះៗដែលបង្ហាញពីកិច្ចការនេះ។ អនុញ្ញាតអោយគេសរសេរអ្វីមួយដែលគេអាចធ្វើនៅថ្ងៃចូលរៀនបន្ទាប់ក្នុងញការបង្ហាញថា គេជាអ្នកចាត់ការដ៏ល្អរបស់ ព្រះជាម្ចាស់នៅក្នុង ថ្នាក់។

## ១០. ពិភាក្សាកិច្ចការទី៤

អ្នកអាចចំណាយពេលខ្លះទៀតសំរាប់ការពិភាក្សាលើកិច្ចការទី៤ បើអ្នកយល់ថាវារឹតតែជួយដល់កិច្ចការក្នុង ថ្នាក់ នេះ។

## ១១. កិច្ចការ

ក. នៅចុងម៉ោងសិក្សាផ្តល់លំហាត់នៅក្នុងព្រះគម្ពីរ ២កូរិនថូស ៩ :៧ អោយគេធ្វើ។

ខ. កែកិច្ចការទី៣ និង ៤

## ១២. ការវាយតំលៃលើមេរៀន

សូមសរសេរការវាយតំលៃលើការវិវឌ្ឍន៍នៃមេរៀននេះ និងរៀបចំជាស្រេចសំរាប់កិច្ចការបន្ទាប់។

ជំរៅនៃកិច្ចការ

ការកត់ចំណាំ

## ក.តើអ្នកចាត់ការជាអ្វី ?

អ្នកចាត់ការគឺជាអ្នកនៅក្រោមអំណាចអ្នកដែលបានតែងតែតាំងគាត់អោយទទួលខុសត្រូវលើសំភារៈឬគ្រប់គ្រងលើមនុស្សដែលនៅក្រោមបញ្ជារបស់របស់កាត់។

ម្ចាស់ជាអ្នកដឹកនាំ ហើយអ្នកចាត់ការជាអកបំរើម្ចាស់ ។ បើខ្ញុំជាគ្រីស្ទបរិស័ទ ព្រះជាម្ចាស់ជាអ្នកដឹកនាំរបស់ខ្ញុំ បើខ្ញុំជាអ្នកបំរើរបស់ព្រះអង្គនោះខ្ញុំមិនមែនជាចៅហ្វាយទេ។មើលក្នុងកិច្ចការអាជីពរកស៊ីវិញ គាត់តែងតែជាអ្នកគ្រប់គ្រងមនុស្ស។ ការងាររបស់គាត់ជួយអ្នកដទៃ អោយធ្វើជាអ្នកបំរើកាន់តែល្អសំរាប់ចៅហ្វាយ។

**តើអ្នកចាត់ការជាអ្វី ?**

គាត់ទទួលខុសត្រូវមាននាទីទៅ តាមបញ្ញត្តិនៃការទទួលខុសត្រូវដែលគាត់បានទទួលពីម្ចាស់ ឬ ចៅហ្វាយ។ បើអ្នកជាគ្រីស្ទបរិស័ទវិញការទទួលខុសត្រូវរបស់គឺ :

- ពេលអ្នកថ្វាយដប់ភាគរយនិងតង្វាយស្ម័គ្រចិត្ត  អ្នកជាអ្នកថ្វាយតង្វាយ
- ពេលអ្នកសំអាតបន្ទប់ទឹក  រៀបចំគ្រែ អ្នកជាអ្នកថែទាំ
- ពេលនៅក្នុងបន្ទប់សិក្សា ឬ ថ្នាក់សិក្សាអ្នកជានិស្សិត។
- ពេលអ្នកនៅក្នុងបន្ទប់ថ្វាយបង្គំ ឬ ព្រះវិហារអ្នកជា អ្នកអធិស្ឋាន
- ពេលកំពុងនិយាយជាមួយអ្នកដទៃ នោពេលញ៉ាំអាហារ អ្នកជាមិត្ត។
- ពេលអ្នកនៅកន្លែងកំសាន្ត អ្នកជាអ្នកកីឡា។
- ពេលអ្នកកំពុងចាយលុយអ្នកជាអ្នកហិរញ្ញវត្ថុ។

អ្នកចាត់ការស្រីឬប្រុស គ្រាន់តែចាត់ការនៅឯកន្លែងការងារ ដែលគាត់ធ្វើអោយចៅហ្វាយរបស់គាត់។ ប៉ុន្តែពេលនៅឯផ្ទះគាត់មិនមែនជាអ្នកចាត់ការទៀតទេ តែប្រហែលគាត់ជាឪពុកឬប្តី ប្រពន្ធ ឬម្តាយ។ ប៉ុន្តែក្នុងនាមជាគ្រីស្ទបរិស័ទ យើងតែងតែធ្វើការ ឬ " បំពេញកាតព្វកិច្ច " ថ្វាយដល់ព្រះជាម្ចាស់ ។

## ២. តើអ្វីដែលព្រះជាម្ចាស់ប្រទានអោយខ្ញុំចាត់ការ ?

តើខ្ញុំដឹងដោយរបៀបណា ថាព្រះជាម្ចាស់សព្វព្រះហឫទ័យអោយខ្ញុំចាត់ចែង ? ព្រះអង្គមានព្រះបន្ទូលប្រាប់ខ្ញុំ ព្រះអង្គហៅការទទួលទាំងនេះជាវិន័យ ដែលខ្ញុំបានទទួលជាកិច្ចការដែលខ្ញុំត្រូវតែធ្វើ។ ជាសិទ្ធិសេរីភាពនូវអ្វីដែលខ្ញុំត្រូវបានប្រទានមកអោយធ្វើ ប៉ុន្តែខ្ញុំមិនចាំបាច់ធ្វើបើសិនជាចង់។ ផ្ទុយទៅវិញខ្ញុំអាចគ្រាន់តែសរសេរសំបុត្រទៅសួរសុខទុក្ខឪពុកម្តាយនៅឯផ្ទះក៏បាន។

តើអ្វីទៅជាការទទួលខុសត្រូវធំបំផុតដែលព្រះជាម្ចាស់ ប្រទានមកខ្ញុំ? ព្រះគម្ពីរ ម៉ាកុស ១២:៣០ ខ គម្ពីរនេះបានប្រាប់ថា ត្រូវស្រលាញ់ព្រះជាម្ចាស់។ សេចក្តីកត់ចំណាំអ្វីជាការទទួលខុសត្រូវរបស់ខ្ញុំចំពោះសេចក្តីស្រលាញ់ ចំពោះព្រះជាម្ចាស់។ ការទទួលខុសត្រូវធំបំផុតរបស់ខ្ញុំគឺ មិនមែនស្រលាញ់ខ្លួនរបស់ខ្ញុំ មិនមែនស្រលាញ់អ្នកដទៃ តែស្រលាញ់ព្រះជាម្ចាស់។

បើជាសិស្សតើការទទួលខុសត្រូវអ្វីដែលព្រះជាម្ចាស់ប្រទានអោយខ្ញុំ? មានសំនួរមួយដែលប្រឈមមុខនឹងខ្ញុំគឺ " តើអ្វីដែលខ្ញុំត្រូវតែធ្វើក្នុងការសិក្សា? "

- យកចិត្តទុកដាក់
- ស្តាប់
- ចូលរួមក្នុងថ្នាក់
- សួរសំនួរ
- កត់ចំណាំ
- មើលការកត់ចំណាំក្នុងថ្នាក់ឡើងវិញ
- អនុញ្ញាតអោយការបង្រៀនជ្រៀបចូលលក្នុងជីវិត

សួរគេនូវរបៀបបង្ហាញព្រះជាម្ចាស់ថា ពួកគេស្រលាញ់ព្រះអង្គដោយសារការត្រងត្រាប់ស្តាប់ក្នុងថ្នាក់។ ប្រាប់ពួកគេអោយយកចិត្តទុកដាក់ ស្តាប់នៅក្នុងថ្នាក់ មួយនាទីបន្ទាប់មកប្រាប់អ្វីដែលពួកគេបានធ្វើ ដូចជាការយកចិត្តទុកដាក់ស្តាប់និងការបង្ហាញសេចក្តីស្រលាញ់ចំពោះព្រះអង្គ។

ខ្ញុំអាចគិតលឿនជាងមនុស្សនិយាយ ដូច្នេះពេលខ្ញុំស្តាប់នៅក្នុងថ្នាក់ខ្ញុំអាចគិតបានច្រើនពាក្យនាង អ្វីដែល គេកំពុង និយាយ។ តាមរយៈការពិត ជាផ្នែកនៃការយល់ដឹងនេះខ្ញុំពិតជាអាចបង្ហាញនូវអ្វីដែលពាក់ពន្ធ័ជាមួយ សេចក្តី ស្រលាញ់។ ខ្ញុំក៏គិតនូវរបៀបដែលខ្ញុំអាចប្រើតាមរយៈវិធីនេះដើម្បីបង្ហាញសេចក្តីស្រលាញ់របស់ខ្ញុំដល់ ព្រះជាម្ចាស់។

## តើខ្ញុំស្តាប់យ៉ាងណាដើម្បីអោយមានសេចក្តីស្រលាញ់ចំពោះព្រះជាម្ចាស់ ?

- ព្រះគម្ពីររ៉ូម ១២:១១ មិនត្រូវអោយមានមានសតិខ្ជិលច្រអូសឡើយ
- ព្រះគំម្ពីកូឡូស ៣:២៣ គ្រប់កិច្ចការដែលបងប្អូនធ្វើ ចូរធ្វើអោយអស់ពីចិត្ត

វាជាការដែលត្រូវគិត ហើយការគិតជាការងារប្រើខួរក្បាលយ៉ាងសកម្ម។ ការស្តាប់ជូនកាលមិនអាចទទួល យកបាន ដូច្នេះខ្ញុំត្រូវយកត្រចៀកត្រងត្រាប់ស្តាប់ពាក្យរបស់គេអោយបាន។ បើការស្តាប់ទៅជួយខ្ញុំអោយ ស្រលាញ់ព្រះជាម្ចាស់ នោះការស្តាប់នេះជាប្រភេទការស្តាប់ដែលអាចទទួលយកបាន។

ផ្លូវមួយក្នុងចំនោមផ្លូវល្អបំផុតជាច្រើនក្នុងការប្រើសតិរបស់ខ្ញុំ ស្តាប់នៅក្នុងថ្នាក់គឺខ្ញុំត្រូវជ្រើសរើសផ្លូវណា ដែលខ្ញុំអាចយកទៅប្រើបាននូវអ្វីដែលគេកំពុងបង្រៀន។ ទីមួយខ្ញុំសំដៅលើការប្រើដើម្បីជួយដល់ការ ទំនាក់ទំនងរបស់ខ្ញុំជាមួយព្រះជាម្ចាស់ ទីពីជាមួយនិស្សិតដទៃទៀត។ នៅពេលដែលខ្ញុំគិតពីកិច្ចការនេះមានចំនុចមួយដែលនិងជួយខ្ញុំគឺ ត្រូវសរសេរគំនិតសំនើផ្ទាល់ខ្លួន ។
កិច្ចការចំពោះមុខដែលមានអាទិភាពជាងគេ គឺ គួរយក ខគម្ពីរផ្ទាល់ខ្លួន មកចែកចាយនៅក្នុងថ្នាក់ ។ គុណភាពនៃការស្តាប់ជាគន្លឹះនោះគឺ ត្រូវទាញយកនូវអត្ថន័យ។

**ភាពយកចិត្តតុកដាក់ក្នុងនៃការស្តាប់**

- ២ព្រះគម្ពីរ កូរិនថូស ៨:១១

## ឃ. តើរបៀបណាដែលខ្ញុំអាចបង្ហាញថាខ្ញុំកំពុងជាអ្នកចាត់ការដ៏ល្អសំរាប់ព្រះជាម្ចាស់

### ១.ពេលវេលារបស់ខ្ញុំ

ព្រះគម្ពីរអេភេសូ: ៥:១៦

" ត្រូវចេះប្រើពេលវេលា ត្បិតសម័យនេះអាក្រក់ណាស់ " អ្នកខ្លះនិយាយថា " បើខ្ញុំមានពេលថែម ទៀតខ្ញុំកាន់តែអាចសំរេចការងារបានច្រើន ថែមទៀត " នោះមិនជួយអ្វីបានទេ។ គាត់មាន ពេល កាន់តែច្រើនដើម្បីចាត់ចែង តើគុណភាពនៃពេលវេលា ក្នុងការប្រើបានល្អជាងទេ? គោលការណ៍ សំខាន់របស់ព្រះជាម្ចាស់គឺ ថា បើអ្នកស្មោះត្រង់នឹងការងារតូចមួយ ក្រោយមកព្រះជាម្ចាស់នឹង ប្រទានអោយអ្នកថែមទៀត។

បើនិយាយពីពេលវេលារបស់ខ្ញុំ តើខ្ញុំអាចប្រើពេលវេលាដ៏ល្អបំផុតរបស់ដោយរបៀបណា? ធ្វើតារាង ការវិភាគពេលវេលាសំរាប់កិច្ចការសំខាន់បំផុត។

## ង. កំណត់អាកប្បកិរិយាបើធ្វើជាអ្នកចាត់ការសំរាប់ព្រះជាម្ចាស់

ខ្ញុំអាចមានអាកប្បកិរិយាត្រឹមត្រូវ ធម្មតាគ្រាន់តែគិតទៅលើគំនិតទាំងឡាយណាដែលមិនខុសឆ្គង នោះ ខ្ញុំអាចដើរតួរនាទីជាអ្នកចាត់ការសំរាប់ព្រះជាម្ចាស់ បានហើយ ។ នោះជាគន្លឹះថាតើ វាអាចទៅរួច ឬមិន រួចនូវអ្វីដែល ខ្ញុំកំពុងដើរតួជាអ្នកចាត់ការ។

សូមពិភាក្សាព្រះគម្ពីររ៉ូម ១២:១១ និងព្រះគម្ពីរកូឡុសៈ៣:២៣ នូវរបៀបខគម្ពីរទាំងនេះទាក់ទងទៅនឹង អាកប្បកិរិយារបស់ខ្ញុំ។ ខគម្ពីរកូឡុស៣:២៣ដដែរ ហើយនៅខាងចុងខគម្ពីរនេះ យើងឃើញមានអត្ថន័យ " គឺមិនមែនធ្វើសំរាប់មនុស្សលោកទេ " ។ នេះបង្ហាញពីចំនុចឧបសគ្គដ៏អាក្រក់ដែលជាច្រើនដងបានកើត ឡើងចំពោះកិច្ចការបំរើព្រះអម្ចាស់។

## មេរៀនទី៤ : ពិធីលាងព្រះអង្គម្ចាស់

### ១. គន្លឹះសេចក្ដីពិតនៅក្នុងព្រះគម្ពីរ :

ការបំរើដោយផ្លាស់ប្តូរគំនិតគ្នា គឺការបំរើដ៏លូតលាស់ដែលយើងរំពឹងគិតពីហេតុផលរបស់ ព្រះជាម្ចាស់ក្នុងការ បំរើនេះ ។

### ២. ខគម្ពីរគន្លឹះ :

**កិច្ចការ២:៤២**

" សាវ័កទាំងនោះព្យាយាមស្ដាប់សេចក្ដីបង្រៀនរបស់ក្រុមគ្រីស្តទូត រួមរស់ជាមួយគ្នាជាបងប្អូន ធ្វើពិធីកាច់នំប៉័ងនិងព្យាយាមអធិស្ឋាន ។

### ៣. ឯកសារយោងរបស់សិស្ស

ទំព័រទី១៩ និង២២១ ក្នុងសៀវភៅរបស់ សិស្សស៊ីគ្នាទៅនឹងមេរៀននេះ ។

### ៤. អោយអត្ថន័យនៅលើពាក្យផ្លាស់ប្តូរគំនិត ( ៥នាទី )

ចង្អុលបង្ហាញការប្រើពិសេសរបស់វា ដែលសំដៅលើការបំរើ នៅក្នុងព្រះវិហារ ។ ត្រូវបង្ហាញពីនិយមន័យទូទៅដែលសិស្សបានចែកចាយផងដែរ ។

### ៥. សំដៅទៅលើគន្លឹះសេចក្ដីពិតនៅក្នុងព្រះគម្ពីរសំរាប់គោលបំណងមេរៀននេះ

ព្យាយាមបញ្ចេសកាពិភាក្សាដែលថា ស្រាទំពាំងបាយជូរ និងនំប៉័ងដំណាងអោយព្រះលោហិត និង ព្រះកាយ របស់ព្រះយេស៊ូ ។

### ៦. ហេតុអ្វីយើងត្រូវមានការផ្លាស់ប្តូរគំនិតគ្នា

ចំណាយពេលអោយបានច្រើនបំផុតពិភាក្សសថា ហេតុអ្វីយើងត្រូវមានការផ្លាស់ប្តូរគំនិតគ្នា។ អនុញ្ញាតអោយ គេអានព្រះគម្ពីរ១កូរិនថូស ១១:២៣-២៤ ហើយស្វែងរកចំនុច៥ ដែលមួយៗពន្យល់ពីមូលហេតុយើងមាន ការបំរើ ។

### ៧. ១ កូរិនថូស ១២:១២ និង ១២:២៧

ប្រើព្រះគម្ពីរ១ កូរិនថូស ១២:១២ និង ១២:២៧ ពន្យល់ពីអត្ថន័យនៃពៃះកាយព្រះអម្ចាស់ ។ ចង្អុលបង្ហាញនេះមិនមែនសំដៅលើព្រះយេស៊ូទេ ប៉ុន្តែសំដៅទៅលើព្រះវិហារវិញ ( ១កូរិថូស ១១:២៩ ) ។

### ៨. ការសុំផ្ទាល់ខ្លួន

សង្កត់ធ្ងន់ទៅលើការស្នើរចំពោះមូលហេតុ ប្រាំ ដែលថាតើហេតុអ្វីយើងត្រូវមានការផ្លាស់ប្តូរគំនិតគ្នា ។

១. ប្រាប់ពួកគេអោងងាយកត់ចំលងចំនុចទាំងនោះពីព្រះគម្ពីររបស់ពួកគេ ។

២. នៅពេលពួកគេសិក្សា លើការបំរើដោយផ្លាស់ប្តូរគំនិតគ្នា ត្រូវប្រើចំនុចក្នុងនេះ ដើម្បីទាញយកចំនុចថែមទៀត ។

៣. ប្រើការកត់ចំណាំទាំងនេះ គ្រប់ពេលវេលា នៅពេលអ្នកបំរើនៅឯព្រះវិហារ ។

៤. ទោះបីជានៅកន្លែងផ្សេងទៀត នៅក្នុងសកម្មភាពក្រុមក៏ដោយ ។

## ៩. កិច្ចការ

ក. នៅចុងម៉ោងផ្តល់លំហាត់ នៅក្នុងព្រះគម្ពីរកូឡុស ៣ :២៣ អោយគេធ្វើ ។

ខ. កែកិច្ចការទី ៥ " ការងាររបស់ខ្ញុំ "

## ១០. ធ្វើការវាយតំលៃលើមេរៀន

សូមសរសេរការវាយតំលៃលើការវិវឌ្ឍន៍នៃមេរៀន និងរៀបចំជាស្រេច សំរាប់កិច្ចការបន្ទាប់ ។

ជំរៅនៃកិច្ចការ

កំណត់ចំណាំ

## សេចក្តីណែនាំមេរៀន

**១.** អ្នកត្រូវការរៀបចំជើងព្រួលអោយបានសំរាប់មេរៀននេះ។ មេរៀននេះអាចជាការធុញថប់ធ្វើអោយគេមិនចូលចិត្ត ដូច្នេះហើយយើងអាចប្រើស្លាយបញ្ចាំង អោយមើលបង្ហាញពីសកម្មភាពនោះកាន់តែល្អ ។ ហើយចំនុចខាងក្រោមនេះជាចំនុចដែលអាចជួយ :

១. និយមន័យនៅក្នុងសៀវភៅវចនាក្រម

២. រូបភាពថ្មីស្តីពីការបំរើដោយការផ្លាស់ប្តូរគ្នានៅឯព្រះវិហារ។

៣. ការបំរើដោយផ្លាស់ប្តូរគំនិតគ្នាដំបូង

៤. ណែនាំដំណើរនៃកាចែកចាយ

៥. នំប៉័ង និងស្រាទំពាំងបាយជូរ

៦. រូបភាពស្នាដៃទាំងពីរបស់ព្រះយេស៊ូដែលត្រូវបានទំលុះ និងស្នាមហូរឈាម

៧. បញ្ចប់ដោយ លូស៊ី ( រូបកំប្លែងអំពីគ្រប់សណ្តែកដី ) បន្លឺសំលេងឡើងថា" ហេតុអ្វីយើងត្រូវមានការផ្លាស់ប្តូរគំនិតគ្នា ! "

**២.** អ្នកអាចចង់ចំនាយពេលវេលាទៅលើអំពើបាប និង ការផ្លាស់ប្តូរគំនិតគ្នា។ ការទាក់ទងការយល់ដឹងនៃព្រះកាយរបស់ព្រ ះអម្ចាស់មាននៅក្នុងព្រះគម្ពីរអេភេសូ ៤:១៦ សរីរាង្គនិមួយៗជាផ្នែក របស់រូបកាយហើយតែងតែជួយទៅវិញទៅមក។ តើខ្ញុំជួយរូបកាយដោយអនុញ្ញាតអោយអំពើបាប បន្សល់នៅក្នុងជីវិតរបស់ខ្ញុំឬ? **<u>ទេ</u>** !មិនដូច្នេះទេ

# មេរៀនទី៥:	ពិធីជ្រមុជទឹក

## ១.	គន្លឹះនៃសេចក្តីពិតក្នុងព្រះគម្ពីរ :

ពិធីជ្រមុជទឹកជាពិធីផ្តល់អាកាសអោយខ្ញុំមានទំនាក់ទំនងរបស់ខ្ញុំផ្ទាល់ជមួយនិងព្រះជម្ចាស់។

## ២.	ខគម្ពីរគន្លឹះ :

**រ៉ូម ៦ :៣**

" *តើបងប្អូនមិនជ្រាបទេឬ យើងទាំងគ្នាដែលបានទទួលពិធីជ្រមុជទឹក ដើម្បីរួមជាមួយព្រះគ្រិស្ត យេស៊ូ នោះគឺ យើងបានជ្រមុជជាមួយព្រះអង្គដែលបានសោយទីវង្គត ។* "

## ៣.	ឯកសារយោងរបស់សិស្ស

ទំព័រទី២២- ២៤ ក្នុងសៀវភៅរបស់សិស្សស៊ីគ្នានឹងមេរៀននេះ។

## ៤.	អត្ថន័យនៃពិធីជ្រមុជទឹក

នៅក្នុងថ្នាក់ចំនាយពេលអោយបានច្រើនបំផុត ពិភាក្សាអំពីអត្ថន័យផ្នែកព្រលឹងវិញ្ញាណដែលពាក់ពន្ធ័ទៅនឹង ពិធិជ្រមុជទឹក។ សូមមើទំព័រទី ២២នៅក្នុងសៀវភៅរបស់សិស្ស ជាពតិមានបន្ថែមលើកិច្ចការនេះ។

## ៥.	ពិធីជ្រមុជទឹកគ្រាន់តែជាសញ្ញាមួយ

ធ្វើយ៉ាងណាអោយពួកគេបានយល់ថា ពិធីជ្រមុជទឹកគ្រាន់តែជាសញ្ញាមួយ មិនមែនជាពិធីលោះបាបរបស់ខ្ញុំ
ទេ។

## ៦.	ចំនុច ខ -ឃ

ពិនិត្យ ចំនុច ខ- ឃ ដោយសង្ខេបក្នុងសៀវភៅរបស់សិស្ស ។

## ៧.	ពន្យល់ដោយសង្ខេបនូវភាពខុសគ្នារវាងពិធីជ្រមុជទឹកនិងពិធីជ្រមុជដោយ ព្រះវិញ្ញាណ។

## ៨.	ការស៊ុំផ្ទាល់ខ្លួន

សង្កត់ធ្ងន់ទៅលើការស៊ុំផ្ទាល់ខ្លួន ធ្វើយ៉ាងណាអោយការទំនាក់ទំនង របស់ខ្ញុំជាមួយព្រះជាម្ចាស់បានប្រសើរ ។ នេះជាចំនុចកាន់តែសំខាន់ថែមទៀតជាងសកម្មភាពនៃពិធីជ្រមុជទឹក។

## ៩.	កិច្ចការ

ក. កែកិច្ចការទី៦ " ពិធីជ្រមុជទឹក "

# មេរៀនទី៦ :    សេចក្តីអធិស្ឋាន

**១.    គន្លឹះសេចក្តីពិតនៅក្នុងព្រះគម្ពីរ :**

គ្រីស្ទបរិស័ទត្រូវការអធិស្ឋានទៅតាមកិច្ចការដ៏សំខាន់ដែលខ្លួនមានក្នុងថ្ងៃនិមួយៗ។

**២.    ខគម្ពីរជាគន្លឹះ :**

**ភីលីព ៤ :៦**

*" សូមកុំខ្វាយខ្វល់នឹងអ្វីឡើយ ផ្ទុយទៅវិញគ្រប់កាលៈទេសៈទាំងអស់ ត្រូវទូលព្រះជាម្ចាស់អោយជ្រាបពី សំនូមពរអធិស្ឋាន និងទូលអង្វរទាំងអរព្រះគុណព្រះអង្គផង ។ "*

**៣.    ឯកសារយោងរបស់សិស្ស**

ទំព័រទី២៥- ២៨ក្នុងសៀវភៅរបស់សិស្សស៊ីគ្នានឹងកិច្ចការនេះ។

**៤.    ធ្វើអោយកាន់តែងាយស្រួល**

តាំងអារម្មណ៏ទុកដូចជាធម្មតាក្នុងការផ្តោតទៅលើសំភារៈផ្នែក អ្វីៗដោយអ្នកថាមានអារម្មណ៏ថា អ្នកនិងជួយសិស្សរបស់អ្នកបានច្រើនបំផុត ។

**៥.    ចង្អុលបង្ហាញចំនុច ឃ " តើខ្ញុំគួរតែអធិស្ឋានដោយរបៀបណា? "**

ចង្អុលបង្ហាញចំនុច ឃ នូវគំនិតសំខាន់ខ្លះៗសំរាប់គ្រិស្តបរិស័ទថ្មី។

**៦.    ការស៊ុំផ្ទាល់ខ្លួន**

សង្កត់ធ្ងន់ទៅលើកាស៊ុំផ្ទាល់ខ្លួនក្នុងការ បង្កើតសេចក្តីអធិស្ឋានចំពោះអ្វីៗដែលមានកាងាយស្រួលៗបន្ទាប់មកឈានទៅសេចក្តីអធិស្ឋានសំរាប់ជីវិតប្រចាំថ្ងៃ។

ផ្តោទៅលើគំនិតដែលនិយាយពីព្រះជាម្ចាស់ជាអ្នកដឹកនាំរបស់ខ្ញុំចំពោះស្ថានការណ៏និមួយៗដែលជួបពេញទាំងមួយថ្ងៃ។

ជំរៅនៃកិច្ចការ

កំណត់ចំនាំ

## ពេលខ្ញុំអធិស្ឋានតើខ្ញុំគួរទូលថ្វាយព្រះជាម្ចាស់អំពីអ្វី?

១. ទូលថ្វាយព្រះជាម្ចាស់នូវអ្វីដែលអ្នកចូលចិត្តអំពីព្រះអង្គ។

២. អរព្រះគុណដល់ព្រះអង្គដែលបានជួយអ្នកក្នុងការឆ្លើយតបជាមួយព្រះបន្ទូលរបស់ព្រះអង្គនិង សំខាន់បំផុតថ្ងៃនេះ។ ភីលីព ៤:៦

៣. ពិភាក្សាជាមួយព្រះអង្គនូវស្ថានការណ៍ទាំងឡាយដែលអ្នកត្រូវការព្រះបន្ទូលរបស់ទ្រង់និងការ បង្រៀនដែលឆ្លើយតបទៅក្នុងបទពិសោធន៍ប្រចាំថ្ងៃ។

៤. អធិស្ឋានតាមការណែនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ អេភេសូ ៦:១៨

ខ្ញុំត្រូវការទូលថ្វាយព្រះវិញ្ញាណបរិសុទ្ធ ។ រៀបចំខ្លួនរួចជាស្រេច ក្នុងការអធិស្ឋានរងចាំ ព្រះអង្គ ។ខ្ញុំត្រូវការយកចិត្តទុកដាក់ស្តាប់អោយបានម៉ត់ចត់តាមរយៈមនសិការរបស់ខ្ញុំ។

៥. អធិស្ឋានសំរាប់អ្វីដែលជាសេចក្តីត្រូវការ។ អេភេសូ ៦:១៨

តើខ្ញុំអងាចប្រព្រឹត្តជាមួយអាកប្បកិរិយារបស់អ្នកបំរើដោយរបៀបណា?

ទូលថ្វាយរឿងនេះទៅដល់ព្រះជាម្ចាស់ដើម្បីអោយព្រះអង្គជួយបង្ហាញវិធីរបស់ព្រះអង្គ។

ទូលសូមព្រះឱវាទរបស់ព្រះអង្គនូវអ្វីដែលព្រះអង្គសព្វព្រះហឫទ័យអោយធ្វើអំពីបង្ហានេះ។

៦. រាល់អ្វីទាំងអស់ត្រូវរៀនអធិស្ឋាន។ ភីលីព ៤ :៦

ពាក្យគន្លឹះអំពីចំនុចនេះគឺ " រៀន "

រៀនសង្កេតមើលផ្នែកខុសៗគ្នា ដែលបានទូលទៅព្រះជាម្ចាស់ដែលអ្នកជួប ប្រទះនៅ ក្នុងជីវិតរបស់អ្នក។

## I សេចក្តីអធិស្ឋានធ្វើអ្វីសំរាប់ខ្ញុំ

**ក.** ជួយខ្ញុំអោយរកឃើញព្រះបិតាដែលគង់នៅស្ថានបរមសុខ។ ម៉ាយថាយ ៦ :៩ " អធិស្ឋានដូចលំនាំនេះ: ឱព្រះបិតានៃយើងខ្ញុំដែលគង់នៅស្ថានបរមសុខអើយ ! សូមសំដែងព្រះបារមីអោយមនុស្សលោកស្គាល់ព្រះអង្គ។ "

ខ. ជួយអោយមានលទ្ធភាពទទួលយកព្រះគុណ ជួយផ្គត់ផ្គង់នៅពេលជួបការខ្វះខាត។ ហេប្រឺ ៤:១៦ " ហេតុនេះយើងត្រូវចូលទៅកាន់បល្ល័ង្ករបស់ព្រះជាម្ចាស់ដោយព្រះហឬទ័យប្រណីសន្ដោសទាំងយកចិត្តទុកដើម្បីព្រះអង្គមេត្តាករុណា និងប្រណីសន្ដោសយើងព្រមទាំងជួយយើងនៅពេលណាយើងត្រូវការ។

គ. ជួយខ្ញុំអោយមានសេរីភាព ពេលជួបការតប់ប្រមលល់។ ភីលីព ៤:៦,៧ " កុំខ្វាយខ្វល់នឹងអ្វីឡើយ ផ្ទុយទៅវិញក្នុងគ្រប់កាលៈទេសៈទាំងអស់ត្រូវទូលថ្វាយដល់ព្រះជាម្ចាស់អោយជ្រាបពីសំនូមពរ របសលបងប្អូន ដោយអធិស្ឋាននិងទូលអង្វរទាំងអរព្រះគុណព្រះអង្គផង។ សេចក្តីសុខសាន្តដែលព្រហជាម្ចាស់ប្រទានអោយប្រសើរជាងសេចក្តីសុខសាន្តមនុស្ស។ សេចក្តីសុខសាន្តដែលនឹងជាប់ក្នុងចិត្តនិងសតិរបស់អ្នក តាមរយៈព្រះយេស៊ូ ។ "

**ឃ.** ជួយខ្ញុំទទួលនូវព្រះវិញ្ញាណបរិសុទ្ធ។
កិច្ចការ៤: ១៣ " កាលពួកគេទូអង្វរព្រះជាម្ចាស់ដូច្នោះ រួចហើយកន្លែងដែលគេជួបជុំគ្នានោះ ក៏រញ្ជួយគេបានពេញដោយព្រះវិញ្ញាណបរិសុទ្ធទាំងអស់គា ហើយនាំគ្នាថ្លែង ព្រះបន្ទូលរបស់ ព្រះជាម្ចាស់ដោយចិត្តអង់អាច។

លូកា ១១:១៣ " សូម្បីតែអ្នករាល់គ្នាដែលជាមនុស្សអាក្រក់ ក៏ចេះអោយរបស់ល្អៗទៅកូនចុះចំណេងបើព្រះបិតាដែលគង់នៅស្ថានបរមសុខតើព្រះអង្គនឹងប្រទានព្រពះវិញ្ញាណដ៏បរិសុទ្ធអោយអស់អ្នកដែលទូលសូមពីព្រះអង្គយ៉ាងណាទៅទៀត។ "

**ង.** ជួយខ្ញុំអោយឃើញព្រះហបទ័យរបស់ព្រះជាម្ចាស់សំរាប់ជីវិតខ្ញុំ។
លូកា ២២:៤១-៤៣ " បន្ទាប់មកព្រះអង្គយាងទៅឆ្ងាយពីពួកសាវក័ចម្ងាយ ប្រហែលគេ ចោលដុំថ្មមួយទំហឹងដៃ។ ព្រះះង្គលុតជង្គង់ចុះរួចទូលអង្វរថា : ឱ ព្រះបិតាអើយ !ប្រសិនបើព្រហអង្គសព្វព្រះហឬទ័យ សូមដកយកពែងពីទុកលំបាកនេហចេញអោយឆ្ងាយពីទូលបង្គំទៅ។ប៉ុន្តែកុំអោយតាមចិត្តទូលបង្គំឡើយ គឺអោយសំរេចតាមព្រហហឬទ័យរបស់ព្រះអង្គវិញ។ ពេលនោះមានទេវទូតមួយរូបចុះពីស្ថានបមសុខមកអោយព្រះអង្គឃើញ ដើម្បីលើទឹកចិត្តព្រះ អង្គ ។ "

**ច.** ជួយអោយនៅស្ថិតស្ថេរគឺមិនបាត់បង់នៅពេលព្រះអង្គយាងមក។
លូកា ២១ :៣៦ " ចូរប្រុងស្មារតី និងទូលអង្វរគ្រប់ពេលវេលាដើម្បីអោយអ្នករាល់គ្នាមានកំលាំងឆ្លងផុតពីហេតុការណ៏ទាំងអស់ដែលកើតមាន ហើយដើម្បីអោយអ្នករាល់គ្នាអាចឈរនៅមុខបុត្រមនុស្ស ។ "

## II ឧបសគ្គលំបាកអ្នកអាចមានចំពោះសេចក្តីអធិស្ឋាន

**ក.** មនុស្សដែលគេមមិនសប្បាយចិត្តជាមួយព្រះជាម្ចាស់គេព្យាយាមបង្អាក់ទំនុកចិត្តរបស់អ្នក ចំពោះព្រះជាម្ចាស់ ហើយពេលនោះអ្នកអាចចង់ឈប់អធិស្ឋាន។

យ៉ូប២១:១៥ " តើព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុតជាអ្វីបានជាយើងត្រូវបំរើព្រះអង្គ តើយើងទូលអង្វរព្រះអង្គបានប្រយោជន៍អ្វី ? "

**ខ.** អ្នកអាចមិនជឿព្រះជាម្ចាស់កំពុងស្តាប់នូវពាក្យដែល អ្នកកំពុងអធិស្ឋានទៅកាន់ព្រះជាម្ចាស់ ព្រោះតែទ្រង់ អ្នកមិនអាចមើលឃើញរឺគ្មានអារម្មណ៍ចំពោះទ្រង់ផង។

ម៉ាកុស១១:២៤ " ហេតុអ្វីបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយអោយតែអ្នករាល់គ្នា អធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយនោះព្រះជាម្ចាស់នឹងប្រទាន អោយអ្នករាល់ គ្នាមិនខាន។" , តែអ្នកមាន" ជំនឿ " អ្វីដែលអ្នកទូលសុំ សូមអោយព្រះហឫទ័យ របស់ព្រះអង្គមិនមែនតាមបំនងរបស់អ្នកឡើយ ។

**គ.** ពេលអ្នកជួបរឿងរ៉ាវធំ ប៉ះពាល់ដល់អាម្មរណ៏របស់អ្នក អាចជួបការលំបាកក្នុងការអធិស្ឋាន (រឿងរ៉ាវមកពីស្ថានការណ៏ផ្សេងៗ ក្រុមគ្រួសារ សត្រូវ ។ល។) ។

ចូរចងចាំថាព្រះបន្ទូលរបស់ព្រះយេស៊ូ ( លូកា ១៨ :១ ) " ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នា ពន្យល់សាវ៏កអោយដឹងថាត្រូវតែអធិស្ឋានជានិច្ច មិនត្រូវស្តាយចិត្តឡើយ។" ឬនៅពេលអ្នក

(យ៉ាកុប៥ :១៣ ) " ក្នុងចំនោមបងប្អូនបើមាននរណាម្នាក់កើតទុក្ខលំបាក ទ្រូវអោយគាត់ អធិស្ឋាន បើនណាអរសប្បាយ ត្រូវច្រៀងបទលើតំកើងព្រះជាម្ចាស់។

**ឃ.** ពេលអ្នកត្រូវបានគេកមពូងបៀតបៀន ទុក្ខលំបាកកាន់តែច្រើន។

ម៉ាថាយ៥ :៤៤ " រីឯខ្ញុំវិញសូមបញ្ជាក់ប្រាប់អ្នករាល់គ្នាថា សូមអោយព្រះអង្គប្រទានពរ អោយអស់ដែលបៀតបៀនអ្នករាល់គ្នាផង ។"

## III ហេតុអ្វីបានជាសេចក្តីអធិស្ឋានគ្មានចំលើយ

**ក.** វាអាចជាផែនការរបស់ព្រះជាម្ចាស់មិនដូចគ្នានិងផែនការរបស់យើង ហើយព្រះហឫទ័យរបស់ព្រះអង្គក៏ខុសគ្នានិងបំណងរបស់យើង។

សេចក្តីអធិស្ឋានរបស់យើងគួរតែវិភាគលើព្រះគម្ពីរយ៉ាកុប ៤ :១៤ ,១៥ " បងប្អូនពុំដឹង ថា ថ្ងៃស្អែកជីវិតបងប្អូនទៅជាយ៉ាងណាឡើង ! បងប្អូនប្រៀបបានជាចំហាយទឹក ដែលមានតែមួយភ្លែតរួចក៏រសាត់ទៅបាត់ទៅ។ បងប្អូនគួរតែពោលថា បើព្រះជាអម្ចាស់សព្វព្រះហឫទ័យ នឹងយើងមានជីវិតរស់នៅហើយ យើងធ្វើការនេះ ធ្វើការនោះ ។ " ក្នុងដំណើរជីវិត ត្រូវថ្វាយសេចក្តីអធិស្ឋានរបស់អ្នកទៅក្នុងព្រះហឫទ័យរបស់ព្រះអង្គ។ យ៉ាកុប ៤ :៣ " បងប្អូនទូលសូមដែរតែឥតបានទទួល ព្រោះបងប្អូនទូលសូមដោយបំណងអាក្រក់ គឺបងប្អូនចង់បានសំរាប់តែបំពេញស្រើបស្រាលរបស់ខ្លួនប៉ុណ្ណោះ ។"

ខ. សេចក្តីអធិស្ឋានគ្មានចំលើយព្រោះ

( ទំនុកតម្កើង ៦៦:១៨ ) " បើសិនខ្ញុំមានគំនិតទុច្ចរិតព្រះជាម្ចាស់មុខជាមិនស្តាប់ឡើយ " សុភាសិត ២៨:១៣ " អ្នកណាលាក់កំហុសរបស់ខ្លួន អ្នកនោះពុំអាចចំរើនឡើងបានឡើយ រីឯអ្នកសារភាពកំហុសរបស់ខ្លួន ហើយឈប់ប្រព្រឹត្តអាក្រក់ទៀត នោះព្រះជាម្ចាស់នឹង អាណិតមេត្តា ។

គ. ព្រះជាម្ចាស់នឹងមិនស្តាប់សេចក្តីអធិស្ឋានរបស់ទេ បើខ្ញុំមិនប្រត្តបត្តិតាមព្រះអង្គ ។

សុភាសិត ២៨:៩ " អ្នកនាមិនប្រត្តបត្តិតាមវិន័យរបស់ព្រះជាម្ចាស់ទេ សូម្បីតែពាក្យអធិស្ឋាន របស់នោះ ក៏គួររអោយស្អប់ខ្ពើមដែរ ។

ឃ. លក្ខខ័ណ្ឌនៃចំលើយសេចក្តីអធិស្ឋាន

១យ៉ូហាន៣:២២-២៤ " អ្វីក៏ដោយអោយតែយើងទូលសូម យើងមុខជាទទួលពីព្រះអង្គមិន ខាន ព្រោះយើងកាន់តាមវិន័យរបស់ព្រះអង្គនិងប្រព្រឹត្តអំពើណា ដែលគាប់ព្រះហឫទ័យអង្គ ។ រីឯវិន័យរបស់ព្រះអង្គមានដូចតទៅ គឺ យើងត្រូវជឿលើព្រះនាមព្រះយេស៊ូគ្រិស្ត ជាព្រះបុត្រា របស់ព្រះអង្គនិងត្រូវស្រលាញ់គ្នាទៅវិញទៅមក តាមវិន័យព្រះអង្គប្រទានមកយើង ។ អ្នក ណាកាន់តាមវិន័យរបស់ព្រះអង្គ អ្នកនោះស្ថិតនៅជាប់នឹងព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ក៏ ស្ថិតនៅជាប់នឹងអ្នកនោះដែរ ។ ត្រង់ហ្នឹងហើយដែលយើងដឹងថាព្រះជាម្ចាស់ ស្ថិតនៅជាប់នឹង យើង ដោយសារព្រះវិញ្ញាណដែលព្រះអង្គប្រទាន មកអោយ យើង ។ "

លក្ខខ័ណ្ឌទាំងបួនមានន័យថា :

១. យើងត្រូវតែសារភាពអំពីបាប ។

២. យើងត្រូវរក្សាមនសិការរបស់យើងអោយបានជ្រះស្រលះ ។

៣. យើងត្រូវចេះស្រលាញ់គ្នាដូចបងប្អូន ។

៤. យើងត្រូវតែហាត់រៀនអត់ទោសផ្នែកព្រលឹងវិញ្ញាណ ។

ង. សេចក្តីអធិស្ឋានគ្មានចំលើយទាក់ទងទៅនឹងមន្ទិលសង្ស័យហេប្រឺ ១១: ៦ " បើគ្មានជំនឿគ្មាន នរណាគាប់ព្រះហឫទ័យព្រះជាម្ចាស់បានឡើយ ។ អ្នកចូលមកជិតព្រះជាម្ចាស់ត្រូវតែជឿថា ពិតជាមានព្រះជាម្ចាស់មែន ហើយជឿថាព្រះអង្គនឹងប្រទានរង្វាន់ ដល់អស់អ្នកណាដែល ស្វែងរកព្រះអង្គ ។ "

យ៉ាកុប១ :៦, ៧ " ក៏ប៉ុន្តែអ្នកនោះត្រូវទូលសូមដោយចិត្តជឿឥតសង្ស័យអ្វីសោះ ត្បិតអ្នក ដែលមានចិត្តសង្ស័យប្រៀបបាននឹងរលកសមុទ្រ ត្រូវខ្យល់បក់បោកចុះឡើងទៅតាមខ្យល់ ។ មនុស្សប្រភេទនេះមិនត្រូវនឹកស្មានថានឹងបានទទួលអ្វីពីព្រះជាម្ចាស់ឡើយ ។ "

**សេចក្តីបញ្ចប់:**

ទំនុកតម្កើង ១៤៥ :១៨ " ព្រះជាអង្គម្ចាស់គង់នៅជិតអស់អ្នកអង្វរព្រះអង្គ គឺ អស់អ្នកដែលអង្វរ ព្រះអង្គ ដោយចិត្តបរិសុទ្ធ ។ "

# មេរៀនទី៧:        ការប្រលង

### ១. ណែនាំមុខវិជ្ជាបន្ទាប់ដែលត្រូវធ្វើ:

ក. ចែកចាយក្រដាសកិច្ចការដែលត្រូវធ្វើនៅក្នុងថ្នាក់អោយសិស្ស ។ ណែនាំគេអោយបំពេញថ្ងៃខែលើក្រដាសលំហាត់ កិចការ និងក្រដាសប្រលង។

ខ. ផ្តល់នូវសេចក្តីណែនាំក្នុងកាសិក្សា ឬ កិច្ចការផ្សេងៗដែលត្រូវបញ្ចប់ មុនចូលដល់ការចាប់ផ្តើម សិក្សាមុខវិជ្ជាបន្ទាប់ដែលអ្នកនឹងបង្រៀន។

### ២. ធ្វើការប្រលងលើមុខវិជ្ជានេះ :

មានកិច្ចការពីយ៉ាងនៅក្នុងមុខវិជ្ជានេះ ដែលនឹងត្រូវជ្រើសរើសដាក់ អោយសិស្សប្រលង ។ វិញ្ញាសារមួយត្រូវបានរេបៀបចំឡើងសំរាប់សិស្ស ដែលមានកំរិតខ្ពស់ជាង ពោលគឺចាប់ពីថ្នាក់ទី៥ឡើងទៅ។ វិញ្ញាសារផ្សេងមួយទៀតជាវិញ្ញាសារទី ១ ត្រូវបានរៀបចំសំរាប់សិស្សថ្នាក់ទាបជាង។

### ៣. ត្រូវប្រមូលកិច្ចការពីនិស្សិតដែលអ្នកបានចែកអោយទោះបីគេមិនទាន់បានបញ្ចប់ក៏ដោយ។